# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ : ២៨៥/១៧ សសរ.ច

# សេចក្ដីសម្រេច
## ស្ដីពី
## ការកែសម្រួលសមាសភាពអនុគណៈកម្មការ និងក្រុមការងាររាជធានីភ្នំពេញ ដើម្បីចុះពិនិត្យដោះស្រាយផលប៉ះពាល់សំណង់ ដីធ្លី ផ្ទះសម្បែង និងដើមឈើហូបផ្លែ ដោយសារគម្រោងខ្សែបញ្ជូនអគ្គិសនីជាកងតង់ស្យុង២៣០គីឡូវ៉ុល ភាគនិរតី នៃប្រទេសកម្ពុជា (ជំហានទី១)

## អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៥០៣ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ ស្ដីពីការត្រាស់បង្គាប់តែងតាំងជាអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សាគណៈអភិបាលខណ្ឌ នៃរាជធានីភ្នំពេញ
- យោងលិខិតលេខ ៤៤៩០ លស.អក.ជយគ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១០ របស់អគ្គិសនីកម្ពុជា
- យោងលិខិតលេខ ១៦០/១៦ សសរ.ច ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ របស់រដ្ឋបាលរាជធានីភ្នំពេញ
- យោងតាមការចាំបាច់របស់រដ្ឋបាលរាជធានីភ្នំពេញ។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

## សម្រេច

**ប្រការ ១**.-

ត្រូវបានកែសម្រួលសមាសភាពអនុគណៈកម្មការរាជធានីភ្នំពេញដើម្បីពិនិត្យដោះស្រាយផលប៉ះពាល់សំណង់ ដីធ្លី ផ្ទះសម្បែង និងដើមឈើហូបផ្លែ ដោយសារគម្រោងខ្សែបញ្ជូនអគ្គិសនីជាកងតង់ស្យុង ២៣០គីឡូវ៉ុល ភាគនិរតីនៃប្រទេសកម្ពុជា (ជំហានទី១) មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម **មាន ចាន់យ៉ាដា** | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | **ប្រធាន** |
| ២ - លោក ហ្វូត ហៃ | នាយករដ្ឋបាលសាលារាជធានីភ្នំពេញ | អនុប្រធាន |
| ៣ - លោក វ៉ា សុធា | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ | អនុប្រធាន |
| ៤ - តំណាងឯកឧត្តម ស្នងការនគរបាលរាជធានីភ្នំពេញ | | សមាជិក |
| ៥ - តំណាងឯកឧត្តម មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ | | សមាជិក |
| ៦ - លោក សុខ សម្បត្តិ | អភិបាល នៃគណៈអភិបាលខណ្ឌព្រែកព្នៅ | សមាជិក |
| ៧ - លោក ឃ្លាំង ហួត | អភិបាល នៃគណៈអភិបាលខណ្ឌជ្រោយចង្វារ | សមាជិក |
| ៨ លោក ម៉ូវ ម៉ានិត | អភិបាល នៃគណៈអភិបាលខណ្ឌសែនសុខ | សមាជិក |
| ៩ - លោក សារិន វណ្ណា | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ | សមាជិក |
| ១០- លោក សៀង បូរិន | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីភ្នំពេញ | សមាជិក |
| ១១- លោក សាំ ពិសិដ្ឋ | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ | សមាជិក |
| ១២- លោក ងី ប៊ុនលី | ប្រធានមន្ទីររ៉ែ និងថាមពលរាជធានីភ្នំពេញ | សមាជិក |
| ១៣-លោក គាត វង្ស៊ី | ប្រធានមន្ទីរបរិស្ថានរាជធានីភ្នំពេញ | សមាជិក |
| ១៤-លោក កាំង លាងគ្រី | នាយកទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស | សមាជិក |
| ១៥-លោក ស៊ិន បូណ៌មី | នាយកទីចាត់ការរៀបចំក្រុង | សមាជិក |

**ប្រការ២**.-

អនុគណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម៖

- សហការជាមួយក្រុមការងារដោះស្រាយផលប៉ះពាល់អគ្គិសនីកម្ពុជា ដើម្បីចុះពិនិត្យដោះស្រាយផលប៉ះពាល់សំណង់ ដីធ្លី ផ្ទះសម្បែង និងដើមឈើហូបផ្លែ និងទ្រព្យសម្បត្តិផ្សេងៗរបស់ប្រជាពលរដ្ឋ ដោយសារគម្រោងខ្សែបញ្ជូនអគ្គិសនីជាកងតង់ស្យុង ២៣០គីឡូវ៉ុល ភាគនិរតី នៃប្រទេសកម្ពុជា (ជំហានទី១)។

- ធ្វើការសម្របសម្រួល និងដោះស្រាយបញ្ហាប្រឈមកើតមានឡើងដែលធ្វើឱ្យរាំងស្ទះដល់ការសាងសង់ក្នុងគម្រោងខ្សែបញ្ជូនអគ្គិសនីជាកងតង់ស្យុង ២៣០គីឡូវ៉ុល ភាគនិរតី នៃប្រទេសកម្ពុជា (ជំហានទី១)។

- រាយការណ៍ពីលទ្ធផលការងារ និងបញ្ហាប្រឈម ជូនឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ដើម្បីជ្រាប និងជាមូលដ្ឋានសំរាប់ពិនិត្យដោះស្រាយបន្ត។

អនុគណៈកម្មការនេះ នឹងបន្តការងារដោះស្រាយបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋក្នុងនាមជាគណៈកម្មការដោះស្រាយបណ្តឹងតវ៉ាថ្នាក់រាជធានីភ្នំពេញ ដើម្បីទទួលពិនិត្យពាក្យបណ្តឹង និងដោះស្រាយសមស្របនូវសំណូមពររបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារគម្រោងខ្សែបញ្ជូនអគ្គិសនីជាកងតង់ស្យុង២៣០គីឡូវ៉ុល ភាគនិរតីនៃប្រទេសកម្ពុជា (ជំហានទី១) នេះ។

**ប្រការ៣.-**

ត្រូវបានកែសម្រួលសមាសភាពក្រុមការងារជាជំនួយការអនុគណៈកម្មការរាជធានីភ្នំពេញ ដើម្បីចុះអនុវត្តការដោះស្រាយដោយផ្ទាល់ជាមួយប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១ - | លោក **ហ៊ុក ហួលីម** | នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ | **ប្រធាន** |
| ២ - | លោក លន់ សោ | អនុប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីភ្នំពេញ | អនុប្រធាន |
| ៣ - | លោកស្រី អេង ច័ន្ទធរី | អនុប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី រាជធានីភ្នំពេញ | សមាជិកា |
| ៤ - | លោក ហ៊ិន ប៊ុច | អនុប្រធានមន្ទីរកសិកម្មរាជធានីភ្នំពេញ | សមាជិក |
| ៥ - | លោក ពៅ ម៉េងហៃ | អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ | សមាជិក |
| ៦ - | លោក ខាត់ សុខា | អនុប្រធានមន្ទីររ៉ែ និងថាមពល រាជធានីភ្នំពេញ | សមាជិក |
| ៧ - | លោក ទី ដូរី | នាយករងទីចាត់ការរៀបចំក្រុង | សមាជិក |
| ៨ - | លោក ស៊ឹម សុផង់ | នាយករដ្ឋបាលខណ្ឌព្រែកព្នៅ | សមាជិក |
| ៩ - | លោក សែម ដារិទ្ធ | នាយករដ្ឋបាលខណ្ឌជ្រោយចង្វារ | សមាជិក |
| ១០- | លោក មុត សុវណ្ណ | នាយករដ្ឋបាលខណ្ឌសែនសុខ | សមាជិក |
| ១១- | លោកតំណាងកងរាជអាវុធហត្ថមូលដ្ឋានខណ្ឌព្រែកព្នៅ | | សមាជិក |
| ១២- | លោកតំណាងកងរាជអាវុធហត្ថមូលដ្ឋានខណ្ឌជ្រោយចង្វារ | | សមាជិក |
| ១៣- | លោកតំណាងកងរាជអាវុធហត្ថមូលដ្ឋានខណ្ឌសែនសុខ | | សមាជិក |
| ១៤- | លោកតំណាងនគរបាលខណ្ឌព្រែកព្នៅ | | សមាជិក |
| ១៥- | លោកតំណាងនគរបាលខណ្ឌជ្រោយចង្វារ | | សមាជិក |
| ១៦- | លោកតំណាងនគរបាលខណ្ឌសែនសុខ | | សមាជិក |
| ១៧- | លោកចៅសង្កាត់ពាក់ព័ន្ធក្នុងខណ្ឌនីមួយៗ | | |
| ១៨- | លោកតំណាងនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់សំរោង ខណ្ឌព្រែកព្នៅ | | សមាជិក |
| ១៩- | លោកតំណាងនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់គោករកា ខណ្ឌព្រែកព្នៅ | | សមាជិក |
| ២០- | លោកតំណាងនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ | | សមាជិក |
| ២១- | លោកតំណាងនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ | | សមាជិក |
| ២២- | លោកតំណាងនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ឃ្មួញ ខណ្ឌសែនសុខ | | សមាជិក |
| ២៣- | លោក ង៉ែត កែន | អនុប្រធានការិយាល័យកិច្ចការច្បាប់ និងការដោះស្រាយវិវាទនៅមូលដ្ឋាន | សមាជិក |
| ២៤- | លោកស្រី មាស រតនី | អនុប្រធានការិយាល័យកិច្ចការច្បាប់ និងការដោះស្រាយវិវាទនៅមូលដ្ឋាន | សមាជិកា |
| ២៥- | លោក ប៊ុន ម៉ានិត | មន្ត្រីការិយាល័យកិច្ចការច្បាប់និងការដោះស្រាយវិវាទនៅមូលដ្ឋាន | សមាជិក |
| ២៦- | លោក យៀម ជីវ័ន្ត | មន្ត្រីការិយាល័យកិច្ចការច្បាប់ និងការដោះស្រាយវិវាទនៅមូលដ្ឋាន | សមាជិក |

**ប្រការ៤.-**

ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម៖

- សហការជាមួយក្រុមការងារអគ្គិសនីកម្ពុជាចុះផ្សព្វផ្សាយ វាស់វែង ស្រង់ប្រមូលព័ត៌មានផលប៉ះពាល់ទាំងឡាយ ដែលពាក់ព័ន្ធនឹងគម្រោងខ្សែបញ្ជូនអគ្គិសនីជាកងតង់ស្យុង ២៣០គីឡូវ៉ុល ភាគនិរតី នៃប្រទេសកម្ពុជា ( ជំហានទី១ ) និងសម្របសម្រួលដោះស្រាយការថ្ពាំងថ្នាក់ចម្ងល់នានាជាមួយប្រជាពលរដ្ឋ។
- ធ្វើរបាយការណ៍ពីលទ្ធផលការងារនិងបញ្ហាប្រឈមជូនអនុគណៈកម្មការរាជធានីភ្នំពេញជាប្រចាំ។

**ប្រការ៥.-**

សមាជិកអនុគណៈកម្មការដោះស្រាយផលប៉ះពាល់រាជធានីភ្នំពេញ និងក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានសាមី។

សមាជិកគណៈកម្មការពិនិត្យដោះស្រាយបណ្ដឹងតវ៉ារាជធានីដែលផ្ទេរភារកិច្ចពីអនុគណៈកម្មការដោះស្រាយផលប៉ះពាល់រាជធានី ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណារបស់រដ្ឋបាលរាជធានីភ្នំពេញ ដែលមានខ្លឹមសារផ្ទុយពីសេចក្ដីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧.-**

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ អភិបាលនៃគណៈអភិបាលខណ្ឌព្រែកព្នៅ អភិបាលនៃគណៈអភិបាលខណ្ឌជ្រោយចង្វារ អភិបាល នៃគណៈអភិបាលខណ្ឌសែនសុខ ប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ និងប្រការ៣ ត្រូវអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ល

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៧

អភិបាលរាជធានីភ្នំពេញ

ឃួង ស្រេង

<u>កន្លែងទទួល :</u>
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងបរិស្ថាន
- ក្រសួងរ៉ែ និងថាមពល
- អគ្គិសនីកម្ពុជា

  « <u>ដើម្បីជូនជ្រាប</u> »
- សាមីខ្លួនដូចប្រការ៧

  « <u>ដើម្បីអនុវត្ត</u> »
- ឯកសារ-កាលប្បវត្តិ